THE SCHOOL DISTRICT OF PHILADELPHIA

**Office of Assessment**
Suite 213, Portal A
440 North Broad Street
Philadelphia, PA 19130

# លក្ខណៈនៃការប្រឡង និងកិច្ចសម្រួលនៃការប្រឡង ឃីស្តូន (Keystone)/ការប្រឡងតាមប្រព័ន្ធវាយតម្លៃសាលារបស់រដ្ឋផិនស៊ីលវេញ៉ា (PSSA)

- មានជម្រើសមួយចំនួនជូនសិស្ស *ទាំងអស់* ក្នុងអំឡុងពេលប្រឡង ដូចជា ការបន្ថែមពេលវេលា និងការអានឮៗនូវរាល់សំណួរទាំងអស់នៅក្នុងការប្រឡង គណិតវិទ្យា វិទ្យាសាស្ត្រ ពិជគណិតកម្រិត ១ និង ជីវវិទ្យា និងសំណួរមួយចំនួននៅក្នុងការប្រឡងអក្សរសិល៍ភាសាអង់គ្លេស (ELA) ។ល។

- ជម្រើសមានជូនសិស្ស *ទាំងអស់* ត្រូវបានហៅថា "លក្ខណៈនៃការប្រឡង"។

- ជម្រើសមានជូនសិស្ស Sp. Ed., EL, និង 504 ដែល *ត្រូវការ* ដើម្បីឲ្យពួកគេចូលរួមនៅក្នុងការប្រឡង ត្រូវបានហៅថា "កិច្ចសម្រួល"។ ដូច្នេះ កិច្ចសម្រួលគឺជាទម្លាប់អនុវត្ត ដែលផ្តល់លទ្ធភាពស្មើភាពចំពោះសំណួរប្រឡងជូនសិស្សទាំងនេះ។

- កិច្ចសម្រួល ត្រូវបានបែងចែកជា ៤ ប្រភេទ៖ របៀបបង្ហាញ របៀបឆ្លើយតប ការកំណត់បរិដ្ឋាន និងការកំណត់ពេលវេលា។

- កិច្ចសម្រួលទាំងអស់ដែលមានជូនក្នុងការប្រឡង ឃីស្តូន ក៏មានជូននៅក្នុងការប្រឡង PSSA ផងដែរ។

- **ជាការសំខាន់ណាស់ ដែលត្រូវកត់សម្គាល់ថា បើទោះបីជាកិច្ចសម្រួលមួយចំនួនអាចមានលក្ខណៈសមរម្យចំពោះការប្រើក្នុងការបង្ហាត់បង្រៀន ក៏ប៉ុន្តែកិច្ចសម្រួលទាំងនោះអាចមិនមានលក្ខណៈសមរម្យសម្រាប់ការប្រើប្រាស់នៅក្នុងការប្រឡងជាលក្ខណៈស្តង់ដារ។**

- កិច្ចសម្រួលត្រូវតែមានលក្ខណៈត្រូវគ្នានឹងសេចក្តីត្រូវការរបស់សិស្ស។ សិស្សត្រូវតែមានឆន្ទៈប្រើកិច្ចសម្រួលទាំងនោះ ហើយសិស្សត្រូវតែចូលរួមនៅក្នុងការជ្រើសរើសរបស់ពួកគេ (សូមមើល សេចក្តីបន្ថែម "ប្រភពជំនួយបន្ថែម" នៅក្នុង Accommodations Guidelines for PSSA and Keystone Exams*)។

- ទម្លាប់អនុវត្តល្អបំផុតនៅក្នុងការជ្រើសរើសកិច្ចសម្រួលសម្រាប់ការប្រឡង គឺការប្រើកិច្ចសម្រួលជាប្រចាំជាមួយសិស្សមុនពេលប្រឡង និងកត់ត្រាឯកសារអំពីការប្រើប្រាស់ដោយជោគជ័យ។ មិនមែនជាទម្លាប់អនុវត្តល្អឡើយ បើផ្តល់កិច្ចសម្រួលនៅក្នុងស្ថានភាពប្រឡង ដែលសិស្សមិនប្រើជាប្រចាំនោះ។

## កិច្ចសម្រួលមានជូនសិស្ស ELs តែប៉ុណ្ណោះ

មានកិច្ចសម្រួល *ស្ម័គ្រចិត្ត* បីប្រភេទដោយឡែកពីគ្នា ត្រូវបានអនុញ្ញាតជាពិសេសសម្រាប់សិស្ស ELs៖

THE SCHOOL DISTRICT OF PHILADELPHIA

**Office of Assessment**
Suite 213, Portal A
440 North Broad Street
Philadelphia, PA 19130

1. វេចនានុក្រមបកប្រែពាក្យ គ្មាននិយមន័យ គ្មានរូបភាព ឬគ្មានប្រព័ន្ធអ៊ិនធ័រណិត—ត្រូវបានអនុញ្ញាតក្នុងការប្រឡងឃីស្តូន ពិជគណិតកម្រិត១ និង ជីវវិទ្យា និងការប្រឡង PSSA គណិតវិទ្យា និង វិទ្យាសាស្ត្រ **តែប៉ុណ្ណោះ** (មានសម្រាប់សិស្ស ELs **ទាំងអស់** មិនថាពួកគេរស់នៅក្នុងប្រទេសនេះបានប៉ុន្មានឆ្នាំនោះទេ)

2. អ្នកបកប្រែផ្ទាល់មាត់/អ្នកបកប្រែអក្សរ ដែលមានសមត្ថភាព** —ត្រូវបានអនុញ្ញាតក្នុងការប្រឡង ឃីស្តូន ពិជគណិតកម្រិត១ និង ជីវវិទ្យា PSSAs គណិតវិទ្យា និង វិទ្យាសាស្ត្រ និងការវិភាគផ្អែកលើអត្ថបទ [Text Dependent Analysis (TDA)] នៃការប្រឡង PSSA ផ្នែក ELA (**មានតែ**សម្រាប់សិស្ស ELs នៅសាលាសហរដ្ឋ រយៈពេលតិចជាង ៣ ឆ្នាំ ប៉ុណ្ណោះ)

3. កូនសៀវភៅប្រឡង និង ចម្លើយ ជាភាសា អេស្ប៉ាញ/អង់គ្លេស —ត្រូវបានអនុញ្ញាតក្នុងការប្រឡង ឃីស្តូន ពិជគណិតកម្រិត១ និង ជីវវិទ្យា និងការប្រឡង PSSAs គណិតវិទ្យា និង វិទ្យាសាស្ត្រ (**មានតែ**សម្រាប់សិស្ស ELs នៅសាលាសហរដ្ឋ រយៈពេលតិចជាង ៣ ឆ្នាំ ប៉ុណ្ណោះ)

***សម្គាល់៖*** *កិច្ចសម្រួលសម្រាប់សិស្ស ELs ខាងលើនេះ **មិន**មានសម្រាប់ការតាមដាន ឬសម្រាប់សិស្សចេញពីកម្មវិធីនោះទេ។*

***ដើម្បីជ្រាបព័ត៌មានបន្ថែមអំពីលក្ខណៈនៃការប្រឡង និងកិច្ចសម្រួលនៃការប្រឡង សូមប្រើបណ្តាញតភ្ជាប់ (link) ខាងក្រោមនេះ ហើយមើលនៅក្នុងផ្នែក កិច្ចសម្រួល៖**
https://www.education.pa.gov/K-12/Assessment%20and%20Accountability/PSSA/Pages/TestingInformation.aspx

**ចំពោះតួនាទីរបស់អ្នកបកប្រែផ្ទាល់មាត់ និងអ្នកបកប្រែអក្សរ សូមចូលទៅបណ្តាញតភ្ជាប់ (link) ខាងលើ រួចចុចលើ Accommodations Guidelines for ELs.